# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីសម្រេចកែសម្រួលលើកទី២
# លើឯកសារអាជ្ញាប័ណ្ណរួម លេខ ០៣៦ ឯអ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៣
# សម្រាប់លោកស្រី ពោជ គីម
# អាជ្ញាធរអគ្គិសនីកម្ពុជា

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.០២០១.០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-យោងឯកសារអាជ្ញាប័ណ្ណរួមលេខ ០៣៦ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឱ្យលោកស្រី ពោជ គីម នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៣

-យោងលិខិតស្នើសុំពង្រីកតំបន់ចែកចាយរបស់លោកស្រី ពោជ គីម ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៧

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៧ ដល់ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០០៧

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី១១០ នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧

## សម្រេច

### ប្រការ១

កែសម្រួលឯកសារអាជ្ញាប័ណ្ណលេខ ០៣៦ ឯអ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៣ ដែលបានផ្តល់ជូនលោកស្រី **ពោជ គីម** (បន្ទាប់ពីនេះហៅថា "**អ្នកកាន់អាជ្ញាប័ណ្ណ**") សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅទីប្រជុំជនកអណ្តើក ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដោយអនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណពង្រីកតំបន់ចែកចាយអគ្គិសនីបន្ថែមលើតំបន់ចែកចាយអគ្គិសនីដែលមានស្រាប់ (មានបង្ហាញក្នុងផែនទីភ្ជាប់លេខ 036LD-map-Pauch Kim-Rev2-2007 ) ។

### ប្រការ២

ឧបសម្ព័ន្ធទី១ចាស់ នៃឯកសារអាជ្ញាប័ណ្ណលេខ ០៣៦ ឯអ ត្រូវជំនួសដោយ ឧបសម្ព័ន្ធទី១ កែសម្រួលថ្មីដែលមានភ្ជាប់មកជាមួយ ។

### ប្រការ៣

សេចក្តីសម្រេចនេះ និងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយត្រូវក្លាយជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០៣៦ ឯអ។

**ប្រការ៤**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ០៣៦ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។

**ប្រការ៥**

សេចក្តីសម្រេចនេះត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាម ទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០៣៦ ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណ លេខ ០៣៦ ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។

ភ្នំពេញ, ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

## ឧបសម្ព័ន្ធទី១
## តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី
## ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
## លើកទី ១១០ នាថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧

១- តំបន់អនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មចែកចាយ និងផ្គត់ផ្គង់អគ្គិសនី គឺនៅទីប្រជុំជនកអណ្តើក ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។

២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនីនេះ កំណត់ដោយ " ផែនទីកំណត់ព្រំ ប្រទល់លេខ 036LD-map-Pauch Kim-Rev2-2007 " ដែលភ្ជាប់មកជាមួយ ។

៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមានបំណងស្នើសុំពង្រីកតំបន់ចែកចាយថែមទៀត ពេលនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជា តាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសម្រេចអនុញ្ញាតឱ្យពង្រីកតំបន់ចែកចាយណាមួយ ឧបសម័ន្ធទី១ នេះត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យពង្រីកតំបន់ចែកចាយនោះ ។

លក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះមានខ្លឹមសារដូចអាជ្ញាប័ណ្ណលេខ ០១៥.ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិការ ឆ្នាំ២០០២ ។ប្រសិនបើចង់ពិនិត្យមើលខ្លឹមសារ សូមពិនិត្យមើលផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។